វិលវិញមកបាន ។

យន់យល់ចំណី ចិត្តទេសពិសី ពិសេសមែនមាន

ទើបអ្នកគន់គិត ក្នុងចិត្តរះញាន រៀងមកពុំមាន

ដែលយល់ដូច្នេះ ។

ឥឡូវយល់ប្លែក ដ្បិតបានជន់ស្បែក មកទុកនៅនេះ

សមជន់នេះឯង គាត់តែងដូច្នេះ ម្តេចឡើយមកបេះ

ធ្វើតាំងចំណី ។

ទើបអ្នកភោក្តា ភស្តុភោជន៍ទុជា ចិត្តទេសពិសី

ពីសាត្រកាល អាហារថ្មោងថ្មី សីងចិត្តអំពី

សម្តេចឥន្ទ្រា ។

បរិភោគស្អប់ស្អល់ អាហារសេសសល់ ឲ្យសុខា

ពិសេសចំណី ចិត្តពីស្វគា ពែករេះចរចា

ដូចមនុស្សវិស័យ ។

ក្នុងពគ្រីនោះ អ្នកផ្តុលគល់លុះ សុំយោទុជ័យ

ទៀតទើបកុមារ ពិសាលផ្កាថ្ងៃ អ្នកចេញទៅព្រៃ

ដំរះចម្ការ ។



ក្រោយនោះក្សត្រី នាំងចេញអំពី ជន់ស្បែកម៉ីមា

រៀបភោជនាហារ ភ័ស្តុភារទុជា ទៅដងគន្លា

មកដាក់ពេញពាង ។

រៀបបោសទីបាន ទុកដាក់ធនធាន ស្រេចហើយទើបនាង

ស្រីស្រស់ធីតា យាត្រាយាសយាង ចូលក្នុងជន់ខាង

ដំណេកប្រក្រតី ។

ឯចៅភោគកុល កុមារនិមិល ចាំងដម្រះទី

បម្ការដល់ថ្ងៃ វិលវិវីងខ្ចី ដើរដល់មកពី

លំនៅគាត្មា ។

យល់ភោជនាហារ សីងចិត្តត្រកាល ពិសេសពិសា

រៀបទុកនៅបាន អ្នកញ្ញានគិតថា ចំណីនេះជា

អស្ចារ្យពន់ពេក ។

មានរសពិសា ពិសេសជាតិជា អាហារប្លែក

អញគិតទៅឆ្ងល់ ឲ្យដល់ថ្ងៃស្អែក លបមើលនឹងភ្នែក

ឯងឲ្យយល់ជាក់ ។

គិតស្រេចព្រះអង្គ ពូជពោធិវង្ស បរិភោគភោជន៍ភ័ក្ស

បរិបូណ៌ស្កប់ស្កល់   សេសសល់នោះអ្នក   កៀរគោះផ្ទេរដាក់
ឲ្យក្ដែគោក្តា ។
ព្រះពង្សពោធិ   ផ្ទុំក្នុងពត្រ   លុះស្រាងសុរិយា
ចុះបាកមណ្ឌល   លុះដល់បង្គារ   ទើបអ្នកលីលា
វិលវិញមកចាំ ។
ពួនពីងភក្ត្រា   ខានខ្ទមបង្គារ   នៅប្រែបដំណាំ
ព្រះនេត្រទំព្យថ្ងៃ   រំពៃគយឃ្លាំ   មៀងមើលចំណាំ
ចង់ដឹងការកល ។
កាលនោះទេវី   រក្សាជនារី   វរវិសេសសល់
នាងដឹងជាក់ជា   ព្រះមហាទសពល   ពួនពីងចង់យល់
រូបនាងទេវី ។
ទើបនាងវរវង្ស   ចេញពីក្នុងថង់   មករៀបចំណី
គោជនកស្តុអាហារ   ដូចកាលប្រក្រតី   ប្រោសមណ្ឌលទី
លំនៅគ្រឹហា ។
ឯព្រះពោធិ   យល់នាងនារី   រក្សាជកញ្ញា
ទ្រង់រូបឧត្តម   ស្ងួតស្តីសមលក្ខណា   ព្រះភ័ក្ត្រជ្រះថ្លា



ដូចចន្ទ្របូណ៌មី ។
កេសាខ្មាញ់ខ្មៅ   ទីងទុបតាទៅ   ដូចស្លាបក្ងួរី[១]
ព្រះខាត់[២]សោភ័ន   ដូចចន្ទមោលី[៣]   លឿងលៀមរស្មី
ខៀវខ្ចីមជ្រះថ្លា ។
ព្រះកាណ៌[៤]តាំងសង   រសរង់ដូចខង   កន្ត្រសុវណ្ណ
ព្រះនេត្រដូចនីល   ស្រស់ស្រិលសោភា   ព្រើសព្រះលលាដ៍[៥
ដូចពពិលមាស ។
ក្ងះមាត្រទ្រខ្ចួយ[៦]   កោងដូចចង្កួយ   កៅទ័ណ្ឌវេរភស[៧]
ព្រះនាសាសម   ឧត្តមពិលាស[៨]   ដូចកន្ទ្វេរមាស
ស្រួលស្រស់សោភា ។

---

១-កន្ទង់ ។ ២- ថ្ពាល់ ។ ៣- តាមរូបស័ព្ទត្រង់ ១ គឺផ្នូងឬកំប៉ោយព្រះច័ន្ទ ។ តែតាមទំនងសេចក្ដី ទំនងជាមិនសម ព្រោះព្រះច័ន្ទមានតែរង្វង់មូលគ្មានកំប៉ោយទេ ។ ខ្ញុំប្រុះ គួរសន្និដ្ឋានថា «ចន្ទមោលី» ក្នុងទីនេះ គឺរង្វង់កណ្ដាប់ជុំវិញនៃមណ្ឌលព្រះច័ន្ទ ដែលយើងតែងសង្កេតឃើញមានព័ណ៌លឿងណាយចំរុះដោយព័ណ៌ខៀវផង? ឬក៏ ពាក្យនេះ សរសេរឬបារឡៀងឃ្លាតក្លាយមកពីពាក្យថា ចន្ទបូណ៌មី ទេដឹង ? ។ ៤- ត្រចៀក ។ ៥- ថ្ងាស ។ ៦- បំពើ្ងមរាងងន្ទបខេស្វយឬគេតត់ខ្សែកោង ។ ៧- ធ្នូស្អាតល្អ ។ ៨- ពិលាសៈ សមរម្យគតខ្ពោះ ។

គន់ទៅខឹមរឹម(១) ព្រះខស្នប៉ប្រិម ប៉ប្រែជិតស្មា
ទោធោយផ្អិនផ្អៀ គន់ទៅខន្ធា ដូចទីលទេនា
រៀបរៀងប្រពិត ។
គន់ព្រះសូវគ្គ(២) មូលម៉ដ្ឋឥតឆ្គង ផ្ទត់ ៣ ជាន់ជិត
អង្គ្រគូតាង(៣) រៀវរាងល្អគាត់ ព្រះមណីព័ន្ធព័ន្ធ
កកបលក្ខណា ។
ហត្ថគ្គលី(៤) ទាំងទសសោភី(៥) ដូចទង់លតា-(៦)
មាសម័យទន់ភ្លន់ ល្អាស់ល្ងន់ថ្លៃថ្លា ផ្ទើរឿងសោភា
សោភ័ងគួរគាប់ ។
គន់ព្រះថនា(៧) ពង់ពីទុក ដូចផ្លែទន្លាប់
ក្បោះក្បំទាំងគូ ត្រឹមត្រូវស្រេចស្រាប់ ដូចជាងចិត្តផ្ចាប់
ផ្ចាប់ផ្ចាល់ទុក ។
ព្រះអង្គេកាយ(៨) យង់យល់ពព្រោយ សូស្គសមអង្គ
ព្រះជង្ឃ(៩)ព្រះបាទ ស្អាងស្អាតសោភា គប់ព្រះលក្ខណា

១-ព្រះខស្ន,បច្ចាមាត់ ។ ២-ក ។ ៣-ស្មាទាំងគូរីកកន្ទែក ។ ៤-ម្រាមដៃ ។ ៥-ល្អគ្រប់ទាំង១០ម្រាម ។ ៦-ទងវល្លិមាស ។ ៧-ស្តន,ដោះ ។ ៨-ក្រពាក,ចង្កេះ ។ ៩-ស្មងជើង ។



ប្រាំប្រការកល ។
អ្នកទតយល់ជាក់ ត្រាំត្រូវភ្ញាក់ភ្ញាក់ អរគេផ្ដឹមដល់
ក្តួចកើតស្នេហា ជីតានិមិល ស្មើរនឹងទប់ទល់
ស្មារតីពុំបាន ។
គន់គិតថៃថា នាងមកពីណា មកនៅនាឋាន
មានរូបល្អក្រៃ ប្រពៃកល្យាណ ក្នុងស្រុកនេះគ្មាន
ស្រីណាផ្ទឹមផង ។
ឬមួយកិន្នរ ទេពតានាគនរ កាឡាល្អផង
គួរអញជណ្តឹង ដំណឹងទំនង ដំណើរដើមទង
តើមកពីណា ។
ទើបអ្នកបរទៅ ទៀងលើលំនៅ ដល់ដណ្តឹងថា
ហៃនាងពិសី ប្រិមប្រិយសោភា នាងមកពីណា
ដូចដល់ឋានអាយ ។
មាតាបិតា ទីឋានមាគ៌ា នៅទៀបឬឆ្ងាយ
នាងមកនេះតើ មានបើក្រងាយ ដូចម្តេចប្រាប់ប្រាយ
ឲ្យបានដឹងក៏ ។ >>

វត្តកជនារី ទទួលអគ្គអគ- រាជវរបវរា
ជាខ្ញុំនៅទី បុរីមាគធ សត្តកុដកជមហា
នគររម្យរ័ត្ន ៗ
ជាបុត្រក្សត្រា សត្តកុដកជា សេពសោយសម្បត្តិ
ពស្ត្រាសពលពង្ស ចតុរង្គបរិសទ្យ សម្រាប់មហាក្សត្រ
គង់គាល់គ្រៀបគ្រា ៗ
កាលក្នុងរាត្រី ពារពេញបូណ៌មី សម្តេចឥន្ទ្រា
ស្តេចហោះទៅឋាន ដល់ឋានបិតា ហើយសុំខ្ញុំជា
បុត្រីព្រះអង្គ ៗ
ព្រះឥន្ទ្រស្តេចយក នាំខ្ញុំហោះមក ហិចហោះគ្រាប់គ្រង់
ដល់ដែនចំការ កាឡាជាចង់ ដាក់ខ្ញុំនៅក្នុង
ចង់ហើយស្តេចទៅ ៗ
ស្តេចទ្រង់បណ្តាំ អស់អាថ៌កិច្ចកម្ម ទូន្មានប្រដៅ
ហើយទុកអញខ្ញុំ ឲ្យចាំនិត្យនៅ បំរើចមទៅ
ជាម្ចាស់សិរសា ៗ
កាលនោះពោធី ស្តាប់នាងនារី ត្រាសព្រះភក្ត្រា



អតេតថ្លែងថ្លឹង នាងឧបមា ត្រេកសោមនស្សា-
ទរទើបថ្វាថ្លែង ៗ
ថាហៃប្អូនស្ងួន បុណ្យបងបានជួន ជួបនឹងប្អូនឯង
បានបេះបុប្ផា ផងគ្នាពីព្រេង ប្រដាប់ពាក់តែង
ថ្វាយព្រះជិនស្រី ៗ
ទើបជាតិឥឡូវ មូលមកជាគូ ស្និទ្ធស្នាលបេតី
ពុំគួរបងបាន រួមហានមេត្រី ជៀតប្អូននៅទី
ទូរស្ថានឆ្ងាយសល់ ៗ
-តាំងនេះហេតុតែ សំណាងបុព្វេ- និវាសផ្គិតផ្គល់
ជូនជួយឲ្យបាន រួមហានមណ្ឌល នឹងប្អូននិម្មល
ជាសាច់សង្សារ ៗ
ទើបអ្នកទុនទប ក្រញូក្រង់ក្រសោប ថ្នាក់ថ្នមធីតា
រួមសេមនោម្យ សុខសមស្នេហា បេតីសន្ធរ
មិត្រមូលមេត្រី ៗ
ទៀនទើបសន្ទត ប្រកបប្រាកដ នាមនាងនារី
ឈ្មោះនាងសុខុមា- លន្ទាទេវី ចាប់ដើមអំពី

សម័យនោះនៅ ។

ទើបនាងយកថង់ ស្បែកទៅទុកត្រង់ ទីឋានល់នៅ

ដែលព្រះឥន្ទ្រា ទេពចមទៅ អធិដ្ឋាននៅ

ខេត្រគន្ធាងចំការ ។

ស្រេចនាងវិលវិញ វិលមកនៅទីឯ គោតកុលកុមារ

រួមរក្សាស្មោះសរ សាទរស្នេហា បំរើព្រះស្វា-

មីមិនមានហ្មង ។

## បទពំនោល

១-កាលនោះអសមហាជនជង ដែលស្គាល់ស្នេហ៍ស្នង នឹងចៅកោតកុលកុមារ ។

ដើរទៅកលេងត្រអាល យល់នាងត្រកាល ស្រស់សុខុមាលម្ល៉ា ។

ទ្រង់រូបឆើតឆាយសោភា ដូចព្រះចន្ទ្រា ទើបពារពេញបូណ៌មី ។

ទីឯគិតទីឯគនរកស្រី និត្យនៅផែនដី ផ្កាល់ផ្ទឹមប្រៀបត្រឹមមិនមាន ។

ប្រកបបញ្ចពិធកល្យា- ណីនៅរួមឋាន(១) នឹងចៅកោតកុលកុមារ ។

ជាគូនៃបនៅស្នេហ៍ស្មាល សេពសុខសង្សារ ទីឯមហាបុរសរ៉ូត ។

១– ស្រីដែលមានលំអ ៥ ប្រការគឺ កេសកល្យាណ ល្អសក់ ១ មំសកល្យាណ ល្អសាច់ ១ អដ្ឋិកល្យាណ ល្អឆ្អឹងគឺធ្មេញ ១ ឆវីកល្យាណ ល្អសម្បុរស្បែក ១ វយកល្យាណ ល្អវ័យ ១ ។



មហាជនសរសើរគ្រប់មាត់ពាក្យនោះពុំស្ងាត់ ដឹងដល់ទៅតាមគោដក(១)

ជាចៅមឿងនៅក្នុងស្រុក ទៅមើលនាងសុ- ខុមាលម្លាទេវី ។

យល់ល្អលើសលែងនារី ប្រដូចកលស្រី ទិព្វទេពអប្សរសួគ៌ា ។

ងាប់ចិត្តគន់គិតថែថា បើអញយកជា ភរិយាពុំសមសេចក្តី ។

គួរជាអគ្គមហេសី ក្សត្រាធិបតី ធិរាជឥស្សូរសិរីសោ ។

ទើបតាមគោដកយាត្រា វិលទៅគ្រឹហា គំបន់លំនៅបានបិត ។

ហឫទ័យមៃៗ គន់គិត កាចកានទុច្ចរិត អធម្មកាម(២) ប្រុស្សា ។

ស្រេចឡើងទៅគាល់ក្សត្រា ក្រុញក្រាបទូលថា បពិត្រអម្ចាស់សិរសើ ។

-ដ្បិតខ្ញុំបានយល់រូបស្រី មួយមិញមានប្តី កំសត់ទុគ៌តក្រោ ។

នាងនោះមាននាមធាយា ដូចស្រីសួគ៌ា ត្រចះដូចចន្ទបូណ៌មី ។

កបបញ្ចពិធកល្យាណី ល្អលើសលែងស្រី នៅក្នុងជម្ពូទ្វីបា ។

គួរតែអម្ចាស់ថ្លៃថ្លា យកនាងមកជា សម្តេចព្រះអគ្គមហេសី ។

ព្រះបាទព្រហ្មទត្តចក្រី ស្តេចស្តាប់សំដី ពាក្យតាមគោដកក្រាបទូល ។

២៦-ថ្ងៃពីក្សត្រត្រកូល ទើបក្សត្រឥស្សូរ មានព្រះបន្ទូលទៅខ្ញុំ ។

ហៃតាមគោដកមន្ត្រី ពាក្យចៅស្រដី គិតនឹងយកភរិយាគេ ។

១–មេស្រុកឬចៅហ្វាយស្រុក ។ ២–ប្រាថ្នាមិនត្រូវធម៌ គឺសេចក្តីចង់បានខុសច្បាប់ ។

ប្តីនោះមិនមានទោសទេ ពាក្យចៅស្រោលស្រែ ពុំគាប់ពុំគួរនឹងច្បាប់ ។
តែមហោសថស្តេចស្តាប់ ស្តេចថាពុំគាប់ ពុំគួរនឹងព្រះហឫទ័យ ។
ខំត្រៀតមូលទៀតវែកវៃ បពិត្រក្សត្រថ្លៃ ទ្រើសទ្រង់ព្រះគុណពណ្ណពយ ។
ខ្ញុំនឹងរិះរកឧបាយ កលកិច្ចគិតថ្វាយ ឲ្យបាននាងរាជធីតា ។
សូមស្តេចប្រើព្រះអាជ្ញា ត្រាស់ដណ្តឹងថា បង្គាប់ទៅចៅគោគកុល ។
ឲ្យរកមាន់មកជាញដល់ លេងលងពាលពល ចង់ដឹងកំឡាំងទទៃ ។
បើមាន់នោះបរាជ័យ ចាញ់មាន់ក្សត្រថ្លៃ សូមស្តេចប្រើព្រះអាជ្ញា ។
ឲ្យទៅយកនាងករិយា មកតំកល់ជា ព្រះអគ្គមហេសីក្សត្រថ្លៃ ។
-ស្តេចស្តាប់សាស័ព្ទសម័យ(១) ព្រមព្រះហឫទ័យ ត្រេកទ្រង់ព្រះសោមនស្សា ។
តាមពាក្យ តាមហោសថថា ត្រាស់ប្រើអាជ្ញា ទៅហៅគោគកុលកុមារ ។
ជាថ្ងៃព្រះរាជឧង្ការ សម្តេចក្សត្រា ដ៏ជាឥស្សរសិរសា ។
ទ្រង់ព្រះបង្គាប់មកថា ឲ្យទៅម្នីម្នា រកមាន់បានមួយយកទៅ ។
ជល់នឹងមាន់ក្សត្របមបៅ កុំផ្សងផ្សូរនៅ ឲ្យទៅឥឡូវឆាប់ ៗ ។
ព្រះពោធិសត្វស្តេចស្តាប់ អាជ្ញាប្រាយប្រាប់ អ្នកព្រួយព្រះទ័យមហិមា ។
ប្រែប្រាប់ទៅប្អូនករិយា ហៃប្អូនពុំងា សំឡូតសំឡាញ់ស្នេហ៍ស្និទ្ធ ។
នេះសមមេស្រុកកាចក្អាត មកយល់ប្អូនរ័ត្ន ទ្រង់ដោយប្រសើរស្រស់ស្រី ។

១ សម័យៈ ហេតុការណ៍ ។



ទើបទៅទូលក្សត្រធិបតី រិះរកកលក្តី ឧបាយនឹងយកប្អូនភ្ញា ។
ឯនាងសុខុមាលន្ទា ស្តាប់ហើយឆ្លើយថា បពិត្រអ្នកជាស្វាមី ។
-ទុកការនេះលើប្អូនស្រី រកមាន់កុំបី អម្ចាស់ព្រួយព្រះចិន្តា ។
ទើបនាងទៅខាងបក្ការ ដែលទីឥន្ទ្រា ស្តេចដាក់ថង់ស្បែកនៅនិត្យ ។
នាងថ្វាយបង្គំតាំងចិត្ត អធិដ្ឋានគិត ដល់គុណព្រះឥន្ទ្រាទ្រង់ ។
ស្រេចនាងលូកទៅក្នុងថង់- ស្បែកទិព្វបញ្ចង់ ក៏បានមាន់ឈ្មោលមួយមានឫ
កម្លាំងខ្លាំងក្រៃហាវហាន នាងនាំមកប្ថាន ឲ្យព្រះស្វាមីចមចៅ ។
-ថាអ្នកយកមាន់នេះទៅ ជាញដល់ភ្នាល់នៅ នឹងមាន់ក្សត្រាធិបតី ។
កាលនោះព្រះពន្សពោធិ៍ សោមនស្សប្រេតី អ្នកបីមាន់ចេញទៅថ្វាត់ ។
ឡើងលើព្រះរាជរោងរ័ត្ន ក្រួញក្រាបប្រណិប័តន៍ បង្គំប្រណម្យនិត្យនៅ ។
ទើបមហាក្សត្រាចមចៅ ព្រះអង្គទតទៅ យល់ចៅគោគកុលកុមារ ។
បីមាន់ចរចូលត្រអាល ស្តេចមានឧង្ការ បង្គាប់ទៅមេស្រុកថា ។
-ឲ្យចៅគោគកុលកុមារ ទៅអង្គុយនា ឋានទីដែលនឹងជល់មាន់ ។
ស្តេចប្រើអាមាត្យខ្ញុំខាន់ ឲ្យទៅយកមាន់ ព្រះរាជទ្រព្យមកថ្វាត់ ។
មាន់នោះមានរូបធំធាត់ មានកម្លាំងក្លាត់ ក្រៃលែងនឹងមាន់នានា ។
ទើបស្តេចបន្ទូលត្រាស់ថា ហៃចៅកុមារ យើងនឹងជល់មាន់លេងលង ៗ

គាល់គ្នា កាលគ្រានោះម្តង មុខមន្ត្រីផង អង្គុយម៉ើរមើលពាសពេញ ។
ថាបើមាន់ចៅផលចាញ់ បរាជ័យមាន់អញ អញឲ្យទៅយកភរិយា ។
នៃចៅមកចុកធ្មើផា ខ្ញុំក្នុងគ្រឹហា បំរើអង្គអញប្រក្រតី ។
ទើបស្តេចឲ្យលែងមាន់ខ្ញី ចូលទៅក្នុងទី ជាន់ស្នាមដែលទីងជាញផល់ ។
កាលនោះមានចៅកោតកុល មើលមើលយល់ ខ្លូមាន់អហាក្យគ្រប្បាស់ច្បង ។
ចចះស្វាបនោះបើងង រអាវំពង វៃតាំពឹងចង់ផល់ ។
ហើរបាក្រទាទៅផល់ វិលវៃកប្ចូកល តាំចឹកនៃមាន់ក្សត្រា ។
ខ្ទាក់ត្កកតាំងស្មឹងសោះសា ងងឹតអន្ធា បាលចាញ់ប្រែតបេញប្លាក់ ។
អស់មហាជនផ្ទុំច្រើនក្តាត់ សោនាបស័ក្ខ យល់ជាអស្ចារ្យគួរស្មង ។
សឹងគន់សឹងគិតកោតក្រែង ឱ្យបខ្ញៀវគ្នាឯង ថាអ្នកនេះមានសិល្បសាស្ត្រ ។
ឯមហាក្សត្រាស្តេចខ្មាស ប្រជាទុកស្ត្រ តាំបេញព្រះស្នូរសោសង ។
កោតកុលដឹងដើមទំនង លាក្សត្រប្រាស់ច្បង វិលទៅលំនៅអាត្មា ។

## បទកាកគតិ

កាលនោះព្រះបាទ ព្រហ្មទត្តនរនាថ ទ្រង់ព្រះចិន្តា
ទីងតាមកោដក មេស្រុកថប់ថា យើងគិតកលប្រា-
កាលម្តេចឥឡូវ ។



ទើបមេស្រុកគិត គាបគាន់ទុច្ចរិត ទូលថាព្រះគូ-
ផរព្រ្ទូធិភជ អំណាចឥតគូ ខ្ញុំតានាទូវ
គិតកិច្ចឧបាយ ។
ចាប់យកភរិយា កោតកុលកុមារ ឲ្យបានតាំងឆាយ
កុំព្រួយព្រះទ័យ ក្សត្រថ្ងៃពណ្ណរាយ ខ្ញុំទីងគិតថ្វាយ
ឲ្យបាននាងមក ។
សូមព្រះអាជ្ញា ត្រាស់ប្រើទៅថា ឲ្យកោតកុលរក
ដំរីបានមួយ ហើយឲ្យនាំយក ដំរីនោះមក
ផល់ទីងក្សត្រថ្ងៃ ។
បើរកពុំបាន តាមតែក្សត្រក្សាន្ត ទីងធ្វើទោសពៃរ៍
ខុសទីងបង្គាប់ ប្រញាប្តូរជៀសជ័យ បានដូចព្រះទ័យ
ប្រាថ្នាពុំឃ្លាត ។
ស្តេចស្តាប់ទំនូល ពាក្យមេស្រុកទូល ទើបក្សត្រនរនាថ
បន្ទូលត្រាស់ត្រង់ ប្រើអង្គអាមាត្យ ថាចៅខ្ទីឃ្នាត
រត់ទៅមើមា ។
ប្រាប់ចៅកោតកុល កុមារទុពិល ឲ្យរកដំ-

សារសោតនាំយក ឲ្យមកដល់គ្នា លេងលេងបេស្កា
កុំឲ្យផ្សេងផ្សេង ។
អាមាត្យនានាំ ព្រះពជបណ្ដាំ យាត្រាត្រាប់ត្រង់
ដល់ពោធិសត្វ រូបត្អូពុំលង់ ថ្លែងដូចព្រះទ្រង់
បង្គាប់សព្វគ្រប់ ។
ព្រះពង្សពុទ្ធា ស្ដាប់ពាក្យអមាត្យ ហើយអ្នកថែរថប់
ព្រួយព្រះចិន្ដា ក៏ត្រាស្ងួតស្ងប់ សញ្ជឹងសញ្ជប់
ពុំចេញថវាចា ។
ទើបវក្យត្រើ ប្រាប់ព្រះស្វាមី គម្ពែងក្រឡា
ជាម្ចាស់កុំគិត ព្រួយចិត្តចិន្ដា ខ្ញុំកេតជា
ឲ្យបានជាម្ដង ។
ទើបនាងទៅត្រង់ ទីដែលដាក់ថង់ អធិដ្ឋានផ្សង
គិតគុណឥន្ទ្រា ទេពព្យាស់ព្យង សូមបានដូចបង
ដូចចិត្តប្រាថ្នា
ទើបនាងល្បុកបុះ ទៅក្នុងថង់នោះ ក្ប្រកើតគជា-
សារសោតសសុទ្ធ ប្រាកដមហិមា បានដូចចិន្ដា



ពិតពុំឃ្លៀងឃ្លាត ។
ភ្លេកជទៅ នាងយកដំរី សារសើហនាទ
នានាំមកដល់ មណ្ឌលឯងអាត្ម ទៀងទើបនាងនាថ
ឲ្យទៅស្វាមី ។
ជាអម្ចាស់យក គជសារសេល្អ នេះនាំទៅខ្ញី
ដល់ទីនគជសារ ក្សត្រាធិបតី អម្ចាស់កុំបី
ធុញថប់បារម្ភ ។
គោត្តកុលកុមារ យល់ដំរីសារ សសុទ្ធស័ក្តិសម
ត្រេកសោមនស្ស ចិន្ដាអរអំ- ណរណាស់រំរំ-
ពេបត្រាច់យាត្រា ។
ដើរដល់ព្រះលាន បង្គំក្សត្រក្សាន្ត ទៀងទើបទូលថា
បពិត្រព្រះអង្គ ប្រើសទ្រង់បេស្កា ខ្ញុំបានគជា
នាំមកជាញដល់ ។
កាលនោះមហាក្សត្រ ព្រះបាទព្រហ្មទត្ត ស្ដេចទតទៅយល់
ដំរីសារស ល្អះល្អមផ្គល ស័ក្ដិសមស្រួស្ដិសល់
ពេកពន់ប្រមាណ ។

ខ្លួនចៅកោតកុល កុមារទុពិល កង្វៀណាខ្សត់ផងបាន
ម្នាក់ឯងឥតត្រើយ ម្ដេចឡើយមកបាន ដំរីពីឋាន
ណានាំមកថ្វាត់ ។
ទើបក្សត្រធិបតី ឲ្យយកដំរី ដ៏យក្ខដំរេក្ខ
បង្គៀងស្លាបមុខ ស្រោបក្នុកល្អក្កាត់ សំងមាសពិចិត្រ
វិត្ថាយរបទា ។
ស្រេចនាំមកថ្កាន ដល់មុខព្រះលាន ទើបស្ដេចត្រាស់ថា
ហៃចៅកោតកុល យើងដល់គជា លេងលង្កាល់គ្នា
បង់ដីងគេដៃ ។
ក្សត្រក្សាន្តគ្រាល ឲ្យលែងគងសារ ទីនាំងនិរភ័យ
បរចូលទៅក្នុង វង្វង់ស្នាមជ័យ មហាជនច្រើនក្រៃ
មើលមីរគ្រៀបគ្រា ។
កាលនោះដំរី ព្រះពង្សពោធី ដញ្ញច(១)ក្ដៀវក្លា
ពេចរត់ដេញដល់ ជាញដល់សោះសា កៀវកៀកពានពារ
ព្រោបព្រះទីនាំង ។

---

១- យកប្រមោយចុកមាត់ហើយបន្ទឹសម្រែកយ៉ាងខ្លាំង ។



គជេន្ទ្រក្សត្រា ញ័រអស់អង្គា ភិតភ័យតាន់តាំង
ក្រេតក្រោតក្រោមក្រុង ស្ទក់ស្ទុតស្ទាំងតាំង ដល់ដួលទៅទាំង
ជំហរស្ទុតស្លាប់ ។
អស់មុខមន្ត្រី ប្រដាពស្ត្រី មកមើលខ្ទាន់ខ្ទាប់
យង់យល់ដំរី ព្រះទីនាំងស្ទាប់ មន្ត្រីអន់អាប់
ចិត្តជាទុក្ខក្រៃ ។
ឯអគ្គមហាក្សត្រ ព្រះបាទព្រហ្មទត្ត យល់គជេន្ទ្រដ៏បេ
ដល់ចាញ់ស្ទុតស្លាប់ អន់អាប់ព្រះទ័យ ទុក្ខទោមនស្សក្រៃ
ពេកពន់ប្រមាណ ។
កាលនោះព្រះពោ- ធិសត្វសេដ្ឋា លុតលាក្សត្រក្សាន្ត
នាំដំរីស ល្អះល្អថ្កើងថ្កាន វិលវិញទៅឋាន
លំនៅអាត្មា ។
ទើបព្រះព្រហ្មទត្ត បើកបន្ទូលថ្វាត់ ដណ្ដឹងអាជ្ញា
ថាចៅកោតកុល ទុពិលកំព្រា គេបានគជា
សារសេនិមិល ។
ចម្លែកមហិមា បាទពីឋានណា នាំមកជាញដល់

ឈ្មោះជ័រជ័យ ក្សីណក្ស័យអញធ្ងល់ អញគិតពុំយល់
ចៅដឹងឬទេ ។

ទើបកជអម្ចា ដែលជាគាថា លុតលើកហត្ថ
ប្រណម្យដាក់ដល់ មណ្ឌលសិរ ទើបទូលថាឯ
កាលខ្ញុំយាត្រា ។

ទៅប្រាប់គោគកុល- កុមារខ្ញុំយល់ គាត់ប្រើកិរិយា
ទៅរកជ័រ អំពីចម្ការ បានមកពីណា
ខ្ញុំពុំដឹងឡើយ ។

ស្តេចស្តាប់ទំនូល អាមាត្យក្រាបទូល ជ្រាបដូច្នោះហើយ
ស្តាយគជេន្ទ្រជ័យ មមៃពុំស្បើយ ទើបក្សត្រត្រាណត្រើយ
ទ្រង់ព្រះចិន្តា ។

នឹងគាមគោជក ជាចៅមឿងស្រុក រឺនវិញទៀតថា
យើងរកកលគិត គំនិតម្តេចម្តា ឲ្យបានកិរិយា
គោគកុលនោះមក ។

មេស្រុកទូលថា បពិត្រព្រះមហា ក្សត្រថ្លៃពន្លក
កុំស្តេចបារម្ភ អញខ្ញុំរិះរក ឧបាយកលយក



នាងថ្វាយឲ្យបាន ។

សូមព្រះចមចៅ ឲ្យដាំទឹកក្តៅ ពុះពន់ប្រមាណ
បើចៅគោគកុល មកដល់រាជដ្ឋាន ត្រាស់ប្រើឲ្យបាន
លូកក្អមទឹកក្តៅ ។

បើខ្លាចពុំហ៊ាន លូកឡើយយល់មាន ទោសទាស់ហេតុហៅ
ខុសនឹងបង្គាប់ ប្រញាប្តិចមចៅ សូមស្តេចឲ្យទៅ
ចាប់យកកិរិយា ។

ស្តេចស្តាប់ស្រាក់ស្រួល ត្រើសព្រមទទួល ធ្វើតាមវាចា
ពាក្យគាមគោជក មេស្រុកបុស្សា ហេតុស្តេចប្រាថ្នា
ចង់បាននារី ។

ទើបប្រើអាមាត្យ មួយរត់ខ្ញាត ទៅហៅពោធី
អាមាត្យទៅដល់ មណ្ឌលឋានទី ទើបថ្លែងថាពី
មហាក្សត្រចមចៅ ។

ស្តេចទ្រង់បង្គាប់ ព្រះរាជប្រញាប្តិ ត្រាស់ឲ្យមកហៅ
ចៅឯងទៅឆាប់ ប្រញាប់ឥឡូវ លង់លូកទឹកក្តៅ
កុំឲ្យផ្សូរផ្សង ។

ឯកជជីកា ពុំពាក្យអមច្ចា នាងយាត្រាត្រង់
ទីឋានបម្ការ យកស្វាពីថង់ មកឲ្យព្រះអង្គ
ជាព្រះស្វាមី ។
ទើបនាងផ្តាំថា ចូរម្ចាស់យកស្វា នេះបៀមទៅទ្វ
ថាបើព្រះមហា- ក្សត្រាធិបតី ធ្វើម្តេចៗក្តី
ម្ចាស់កុំបារម្ភ ។
កោតកុលកុមារ ស្តាប់ពាក្យជាយា ផ្តែផ្តាំសុខុម
អ្នកបៀមស្វានោះ ចរចុះដល់លំ- នៅនៃរោងរម្យ
មហាក្សត្របមទៅ ។
ឯអង្គក្សត្រា យល់ហើយត្រាស់ថា អញប្រើឲ្យទៅ
ហៅចៅឯងមក ឲ្យលូកទឹកក្តៅ ពុះពេញទិត្យនៅ
ក្នុងខ្ទះនេះថ្វាត់ ។
បើលូកពុំបាន ចៅឯងនឹងមាន ទោសទុក្ខទៀងទាត់
អញឲ្យពិឃាត ជន្មជាតិចៅថ្វាត់ រឹបយកសម្បត្តិ
យកទាំងភរិយា ។
ព្រះពោធិសត្វ ក្រញួក្រាបប្រណិប័តន៍ បង្គំទូលថា



បពិត្រព្រះអង្គ ទ្រើសទ្រង់បេស្តា ត្រាស់បង្គាប់ថា
ប្រើអង្គអញខ្ញុំ ។
ឲ្យលូកទឹកក្តៅ ពុះពោរទិត្យនៅ ក្នុងខ្ទះធារធំ
ខ្ញុំនឹងលូកថ្វាត់ ថ្វាយក្សត្រឧត្តម សូមព្រះអង្គអ-
ម្ចាស់ទតឲ្យជាក់ ។
ទើបអ្នកលូកទៅ ក្នុងខ្ទះទឹកក្តៅ ពេញពុះគគ្រាក់
បទបានបៀមស្វា ប្រែជាត្រជាក់ ពុំក្តៅដល់អ្នក
ចុះទាំងខ្លួនទៅ ។
ផ្ទូតលេងក្នុងខ្ទះ ផុសក្អែលផំរះ អសអង្គឥតសៅ
ឥតមានក្រហាយ សប្បាយទិត្យនៅ ក្នុងខ្ទះធំជ្រៅ
កណ្តាលអគ្គី ។
ព្រះបាទព្រហ្មទត្ត យល់អស្ចារ្យក្តាត់ ស្ញប់ស្ញែងបារមី
ទោះទាំងសេនា យោធាមន្ត្រី សោតសឹងស្រដី
កោតក្រែងគ្រប់គ្នា ។
ទើបព្រះពោធិ៍ លីលាឡើងពី ខ្ទះមកលុតលា
វិលវិញទៅឋាន ទីឋានគ្រឹហា លំនៅអាត្មា

ដូចដែលប្រក្រតី ៗ

ក្រោយនោះក្សត្រា ទ្រង់ព្រះចិន្តា គិតនឹងមន្ត្រី
គឺតាមកោដក មេស្រុកអប្រិយ ជាយើងភក្ដី
ឧបាយម្ដេចទៅ ៗ

កាលគិតពីមុន រិះរកកលកុន អសារអាសៅ
ពុំបានគតិយា ថែនវាមកគូរ បំរើគាល់ហៅ
ដូចចិត្តប្រាថ្នា ៗ

ទើបមេស្រុកទូល បពិត្រឥស្សូរ ជាម្ចាស់សិរសា
ខ្ញុំគិតឧបាយ- កលថ្វាយក្សត្រា មួយទៀតយល់ជា
គាប់គួរសុខុម ៗ

សូមស្ដេចត្រាស់ប្រើ អស់ជាងផងធ្វើ ជាគេរដំ(១)
ដាក់មនុស្សចូលទៅ ពួននៅសម្ងំ យកស្បែកពាសអំ-
ពីក្រៅឲ្យជិត ៗ

ឲ្យសែងទៅដល់ ជូនចៅកោតគុល ដាក់ដល់ឋានបិត
ចាំស្ដាប់ពាក្យពេចន៍ កលកិច្ចគំនិត និយាយរិះគិត
ម្ដេចនឹងកិរិយា ៗ

១– ស្ពៃដំ ។



ព្រឹកឡើងយើងយក គេរនោះមក វះយកមនុស្ស
បើឮពាក្យពេចន៍ ម្ដេចៗចរចា យើងដឹងពាក្យវា
សឹងងាយរកកល ៗ

មហាក្សត្រស្ដេចស្ដាប់ ឧបាយកលគាប់ សោមនស្សាសល់
ទើបស្ដេចត្រាស់ប្រើ ជាងធ្វើរបស់ ប្រញាប់ខ្វាយខ្វល់
រូបស្រេចពុំលង់ ៗ

ស្ដេចឲ្យអមច្ចា ជំនិតក្សត្រា ចូលទៅនៅក្នុង
គេរហើយពាស ស្បែកដាសពុំផ្សង ទៀងទើបព្រះអង្គ
ត្រាស់ប្រើអមច្ចា ៗ

សែងគេរទៅ ជូនដល់លំនៅ កោតគុលកុមារ
ស្ដេចទ្រង់បណ្ដាំ កិច្ចកម្មវាជា អាមាត្យលុតលា
ចុះចាកកេងរត្ន ៗ

ហៅគ្នាសែងស្គរ យាត្រាបញ្ចរ ដល់ពោធិសត្វ
ឡើងលើគ្រឹហា ថ្លែងថាមហាក្សត្រ ព្រះបាទព្រហ្មទត្ត
ឥស្សូរសិរសា ៗ

ត្រាស់ប្រើយើងយក គេរដ៏យមក ដាក់ក្នុងគ្រឹហា

ខាងដំណែកទៅ    និត្យនៅករិយា    ឲ្យកើតសុខា
មង្គលសួស្តី ។
បើអ្នកបង់មាន    ប្រាថ្នាចង់បាន    បុត្រាបុត្រី
ប្រាថ្នាយសសក្តិ    ខ្ញុំប្រុសខ្ញុំស្រី    សឹងបានដូចក្តី
ប្រាថ្នាពុំខាន ។
ដ្បិតគេដ័យ    ជាមង្គលក្រៃ    សម្រាប់ក្សត្រក្សាន្ត
ទ្រង់ព្រះមេត្តា    ករុណាប្រោសប្រាណ    ចង់ឲ្យទៅមាន
បុត្រាតទៅ ។
អាមាត្យបង់ចាំ    ថ្វងព្រះបណ្តាំ    មហាក្សត្រចមទៅ
ស្រេចទើបសែងស្គរ    នោះបរបូលទៅ    ដាក់ខាងលំនៅ
ទីអ្នកនិទ្រា ។
អាមាត្យទាំងនោះ    លុតលាចាកចុះ    ចេញបរលីលា
វិលវឹងទៅដល់    មណ្ឌលក្សត្រា    ទើបទូលដោយនា
ដំណើរសព្វគ្រប់ ។
ឯព្រះពោធិ៍    ទូវនាងនារី    លុះល្វាចព្រលប់
បរិភោគភោជនការ    អាហារស្កល់ស្កប់    លង់លុះយូរយប់



បរបូលនិទ្រា ។
ហេតុកម្មមកផ្តល់    នោះនាងនិមិល    នឹងពង្សពុទ្ធា
ឲ្យជាប្រហែស    ទ្វេធ្វេសចិត្តា    ពុំពិចារណា
ពិនិត្យពិស្តារ ។
អ្នកនឹងនាងនាថ    ពុំដែលព្រាត់ឃ្លាត    ក្រេមក្សាន្តសាទរ
ត្រេកអររួមក្រៃ    ស្មោះស្ម័គ្រស្មោះសរ    ក្សត្របវរ
សំណោះបរធា ។
ថាខ្ញុំដំកប    ឲ្យអម្ចាស់ជ្រាប    ដ្បិតព្រះឥន្ទ្រា
ស្តេចដាក់ត្រណម    បន្ទមផ្តាំថា    កុំឲ្យគោគ្គា
ស៊ិតសត្វទាំងឡាយ ។
ស៊ិតមាន់ស៊ិតទា    បើម្ចាស់គោគ្គា    កើតក្តៅក្រហាយ
អស់អង្គអញខ្ញុំ    ពិតពុំសប្បាយ    នឹងទប់ទល់កាយ
និត្យនៅពុំបាន ។
ខ្ញុំរត់វិលទៅ    នគរលំនៅ    បិតាក្សត្រក្សាន្ត
ទូវព្រះមាតា    ថ្វៃថ្វាប្រដាន    ប្រាកដពុំខាន
ដូចពាក្យខ្ញុំថា ។

បើម្ចាស់បេះតម ក្បែរត្រណម ពិតពុំគោក្តា
អស់ទាំងស៊ិតសត្វ ទៀងទាត់សត្យា បាននៅផងគ្នា
លុះអស់ជីវី ។
ឯអង្គអមច្ចា ដែលពួននៅនា ក្នុងស្គរគើ
សឹងមកចាំស្តាប់ នាងប្រាប់ស្វាមី បានស្តាប់សំដី
សំដែងជាក់ច្បាស់ ។
លុះអរុណា— ទ័យទើបសុរិយោ រៀងរះរហ័ស
ពីទិសបូព៌ា ស្តេចមានតម្រាស់ ព្រះបន្ទូលត្រាស់
ប្រើអង្គអមច្ចា ។
ទៅសែនគេហ៍ ជ័យចេញអំពី ផ្ទះពន្ធនា
យកមកដាក់ដល់ មណ្ឌលក្សត្រា រះយកអមច្ចា
ចេញចាកគេហ៍ ។
ស្តេចដណ្តឹងថា អាមាត្យអើយអា បានឮពាក្យពី
គោគកុលកុមារ បរោថាអ្វី នាងតើស្រដី
និយាយថាម្តេច ។
អាមាត្យទូនអង្គ លុតលើកករផ្គង់ ប្រណម្យទូលស្តេច



តាមដោយបានដឹង ដំណឹងពាក្យពេចន៍ ត្រណមការកិច្ច
នាងប្រាប់ស្វាមី ។
ស្តេចស្តាប់ទំនួល អាមាត្យក្រាបទូល ជ្រាបអស់សេចក្តី
ទ្រង់ព្រះចិន្តា គិតថាអំពី មុនមកក្រក្រី
គិតឧបាយកល ។
ច្រើនផងច្រើនគ្រា យកប្រពន្ធរា ពុំបានសោកសល់
រាមានតេជះ តបះឥន្ទ្រពល បេះកិច្ចការគល
សិល្បសាស្ត្រធាប់ធុត ។
បេះគួរគិតផ្ទៀត ផ្ចិតកលរឹងទៀត ឲ្យបាននាងរត់
ទៅនគរឆាយ ឲ្យឆ្ងាយប្រាកដ ឲ្យប្តីកំសត់
នៅតែម្នាក់ឯង ។
ហេតុស្តេចអន្ធពាល គំនិតស្រើបស្រាល ស្ពាតើវង្វើង
ពុំខ្លាចកម្មពៀរ ពាំទៀរអង្គឯង ពុំគិតពុំក្រែង
ភ័យចតុរាបាយ ។
ទើបស្តេចប្រញាប្ត ទ្រង់ព្រះបង្គាប់ ទៅអស់ចៅហ្វាយ
ឃ្លាំងគោជន៍សាលី ពិសេសទាំងឡាយ ឲ្យរៀបស្រាបាយ

ក័ស្តុភោជនា ។
អាហារបំអាប់ បង្អែមជាប សឹងស៊ុតមាន់ទា
ប្រឡាក់លាយឡំ ប្រឡំផងគ្នា ខ្លូខញាំភ្លា
លាយសឹងស៊ុតសត្វ ។
រៀបរួចស្រេចហើយ ពិតពុំលន់ឡើយ ទើបព្រះមហាក្សត្រ
ត្រាស់ប្រើអមច្ចា យាត្រាទៅថ្វាត់ ហៅពោធិសត្វ
នូវអស់មន្ត្រី ។
ឲ្យមកជួបជុំ លើកជពោងរម្យ បរិភោគចំណី
អាមាត្យលុតលា ក្សត្រាធិបតី ទៅហៅសេនីយ៍
សេនាចតុរង្គ ។
ហើយហួសភ្លោះទៅ ទាល់ទីលំនៅ មណ្ឌលព្រះពង្ស
ពន្ធកសាស្តា ថ្លែងថាព្រះអង្គ មហាក្សត្រទ្រើសទ្រង់
តម្រាស់ឲ្យហៅ ។
ទើបអ្នកម្មា ដើរតាមអាជ្ញា ត្រាច់ត្រង់សំដៅ
ឡើងដល់លើបាន ពិមានលំនៅ ពេងរម្យឥតសៅ
ក្រួញក្រាបវន្ទា ។



ជួបជុំមន្ត្រី សេនាបតី ពជវង្សពង្សា
គង់គាល់ដេរដាស ពេញពាសក្រឡា គំនាល់កជា
រៀបរៀនពល់ពយ ។
ស្តេចទតទៅយល់ ពោធិសត្វដល់ អង្គុយពីឆ្ងាយ
ទើបស្តេចត្រាស់ប្រើ ទៅលើចៅហ្វាយ ឃ្លាំងឲ្យលើកបាយ
លើកអស់ចំណី ។
ភោជនាហារ ផ្សេងៗត្រកាល លៀងអស់មន្ត្រី
យោធាពលពង្ស ចតុរង្គសេនីយ៍ ហើយហៅពោធិ-
សត្វសួស្តីសោភា ។
ហៃចៅភោគកុល— កុមារនិម៉ល ចរចូលភោក្តា
ភោជនាហារ ត្រកាលពីសា ជាមួយនឹងអា-
មាត្យមុខមន្ត្រី ។
ពោធិសត្វស្តាប់ ស្តេចត្រាស់បង្គាប់ ឲ្យអ្នកចូលធី
អ្នកដឹងជាមហា- ក្សត្រាធិបតី ផ្ទេកលចំណី
លាយនឹងស៊ុតសត្វ ។
អ្នកគិតថប់ថា បើពុំភោក្តា សមព្រះមហាក្សត្រ

ស្តេចទ្រង់ព្រះក្រោធ ពិរោធខ្ញាល់ក្តាត់ ធ្វើទោសទាល់ទាត់
ដល់ក្ស័យជន្មា ។
ទើបពោធិសត្វ មហាបុរសោត្ត អ្នកចូលគោក្តា
ចំណីអាហារ ក៏ស្តុគោជន៍ឲ្យជា ព្រួយព្រះទ័យា
គិតដល់មហេសី ។
ក្រែងនាងកល្យាណ ទឹងនៅពុំបាន ពុំសុខឥន្ទ្រិយ
ក្រហាយក្រហល់ តែដល់ទៅទី នគរជននី
ជនកជីតា ។

## បទព្រហ្មគីតិ

កាលនោះវេរត្រី នាងនៅទំហាំងត្រីហា
ពុំសុខក្នុងអង្គា កើតជាក្តៅក្រហាយលន់ ។
ទឹងទប់ទឹងទល់ប្រាណ នៅពុំបានទើបស្រែគន់
រំពឹងរំពិះគិតគន់ ជាឲ្យព្រះរៀមស្វាមី ។
សមស្តេចគាប់កំទៀវ ឲ្យមកហៅអ្នកទៅខ្ញុំ
ឲ្យបរិភោគចំណី លាយទឹងសុិតមាន់ពុំខាន ។
ទើបប្អូនទៅឯអាយ ក្តៅក្រហាយពន់ប្រមាណ



ទឹងទំនៅពុំបាន ប្អូនតែទៅស្រុកប្អូនវិញ ។
ឲ្យសមគិតប្រណី ព្រះស្វាមីមិត្រសំឡាញ់
សមសោកៗអម្នេញ ម្នាក់ឯងអន់អួលអាល័យ ។
ខ្លួនប្អូនបាកឃ្លាតឃ្លា ឥតនរណានៅសព្វថ្ងៃ
គ្រាន់ពឹងគ្រាន់អាស្រ័យ នៅកំដរព្រះរៀមរ័ក ។
នាងសៅនាងសោកសោះ នាងអាឡោះអន់អួលអាក់
ជោរជលនេត្រស្រក់ សរស្រោកស្រោចព្រះភក្ត្រា ។
ទើបនាងនាថស្រីថ្លៃ ផ្តាំជាំហៃសុនខា
សសុទ្ធសមសោភា ចូរប្រាយប្រាប់ព្រះស្វាមី ។
ថាអញក្តៅក្រហាយ ពុំសប្បាយក្នុងឥន្ទ្រិយ
ក្តៅក្តាត់ដូចអគ្គី ឆេះពេលពេកអស់អង្គា ។
សុនខអើយចូរស្តាប់ ចូរប្រាយប្រាប់ស្វាមីថា
អង្គអញនេះក្រាបលា ទៅនគរព្រះជនក ។
ទឹងទំនៅពុំបាន ក្តៅក្នុងប្រាណពិតពុំសុខ
ឥឡូវនេះអញទុក តែចិញ្ចៀននេះទាំងដប់ ។
តាងតួអញនេះនៅ ឲ្យបមហៅជាស្វាមី

ដឹងដើមគាថាសេចក្តី　　សមសែនសោយសោកណាស់ ។
បើចិត្តអ្នកស្រឡាញ់　　បង់តាមអញទៅឲ្យដល់
នគរបានមណ្ឌល　　ទីព្រះវររាជបិតា ។
នាងណែប្រាប់ទិសទី　　ទៅអំពីនគរ
នេះឯងដល់ជលសា　　សមុទ្រមួយមានចម្ងាយ ។
ប្រមាណដប់យោជន៍ផ្លោះ　　ទៅពីនោះទៀតទូរឆ្ងាយ
ម្ភៃប្រាំយោជន៍ចម្ងាយ　　ទើបដល់ស្រុកអញនិត្យនៅ ។
នាងផ្តាំសុនខា　　កុំទុក្ខអួលអន់ក្តៅ
ស្រេចនាងយាត្រាទៅ　　តែឯកអង្គដោយមាគ៌ា ។
ផ្អូកផ្អើះទ្រូងគិត　　អួលអាណិតអនាថា
ដោយគេជះធីតា　　តែថ្ងៃមួយដល់បុរី ។
នាងនាថចរចូលដល់　　លើមណ្ឌលមន្ទីរទី (១)
បង្គំព្រះជននី　　នូវជនករាជក្សត្រា ។
ពីរក្សត្រអរនេនទប　　ថ្នមក្រសោបថើបថៃថា
ហៃកូនស្ងួនពុំឆា　　កាលព្រះឥន្ទ្រាធិបតី ។

១- ច្បាប់ខ្លះថា លើមណ្ឌលៗទី ។



មកយកស្ងួនព្រលឹង　　ទៅឋានឯងឲ្យមានប្តី
ឥឡូវមានហេតុអ្វី　　ក៏កូនស្ងួនវិលវឹងវិញ ។
ទើបនាងក្រាបទូលថា　　កាលឥន្ទ្រាយកខ្ញុំចេញ
ហោះទៅដល់អរញ្ញ　　ខាងស្រុកពារាណសី ។
ស្តេចដាក់ខ្ញុំក្នុងថង់-　　ស្បែកព្រះអង្គទុកខាងទី
បម្ការកូនសេដ្ឋី　　ឈ្មោះគោតកុលកុមារ ។
ម្នាក់ឯងឥតសាច់ញាតិ　　ទំសង្វាតធ្វើចម្ការ
មានតែសុនខា　　មួយសសុទ្ធនិត្យនៅផង ។
ថ្ងៃនោះមកយល់ថង់　　ព្រសងផ្ទុំនលូរពង
បន្ទីស័ក្តអំងកង　　ញុះទៅដល់កូនសេដ្ឋី ។
ដើមកយល់ថង់ស្បែក　　ល្អចំខ្សែកយកទៅឱ្យ
ដាក់លើមណ្ឌលទី　　ខាងជំណេកដែលនិទ្រា ។
ខ្ញុំសាតនៅបំរើ　　រៀបសារពើភោជនា
តាមដោយពាក្យឥន្ទ្រា　　បានជាគូនៅនែបនិត្យ ។
នាងទូលពីមស្រុក　　តាមគោជកចិត្តទុច្ចរិត
ទូលមហាក្សត្រគន់គិត　　ទុបាយកលកិច្ចច្រើនគ្រា ។

នាងទូលសព្វសេចគ្រប ឲ្យសម្ដេចព្រះបិតា
មាតាថ្លៃសោភា ស្ដេចជ្រួតជ្រាបសព្វសេចក្ដី ។
ទើបក្សត្រទាំងពីរថា ឱស្ងួនភ្ញាពេញពិសី
ហេតុបុណ្យហេតុបារមី គុណសម្ដេចព្រះឥន្ទ្រា ។
ជៀងជួយដោះទុក្ខភ័យ មានជោគជ័យឈ្នះក្សត្រា
បានរួបស្ងួនពុំងា វិលវិញមកសុខសប្បាយ ។
ទើបនាងក្រាបលាទៅ ទីលំនៅនាងតាមឆាយ
អស់ស្នំស្និទ្ធអត់យោយ សឹងសប្បាយចិត្តគ្រប់គ្នា ។
នាងនាថនៅរងទុក្ខ ពិតពុំសុខក្នុងចិន្ដា
គន់គិតទៅព្រះមហា បុរស័ត្នជាស្វាមី ។
ខ្សឹកខ្សួលអួលអន់អាក់ ព្រួយព្រះកន្ទ្រៃក្សត្រី
ពុំដូចកាលប្រក្រតី ស្ងៀមស្ងួតស្ងប់ព្រះភ័ក្ត្រា ។

## បទកាកគតិ

នេះនឹងនៅនិ- ទានទៅពោធិ- សត្វស្ងួតសោភា
កាលព្រះព្រហ្មទត្ត មហាក្សត្រពាលា ហៅទៅគោត្តា
ភោជន៍ភ័ស្ដុចំណី ។



លុះថ្ងៃជ្រៀងជ្រេ សុរិយាទន់ទេរ ទើបព្រះពោធិ
ក្រួញក្រាបលុតលា ក្សត្រាធិបតី វិលវិញមកទី
លំនៅអាត្មា ។
ឡើងលើមណ្ឌល មៀងមើលពុំយល់ ភ្នែកជងគា
ភាំងគិតស្ងុតស្ងួង ដណ្ដឹងសុនខា នាងដើរទៅណា
ក៏បាត់ពុំយល់ ។
សុនខថ្លាស់ឆ្លើយ ថាអម្ចាស់អើយ ក្សត្រីនិមល
ពុំសុខសប្បាយ ក្រហាយក្រហល់ នឹងនៅពុំស្កល់
អន្ទះអន្ទែង ។
រត់ទៅរត់មក ដជ្រួលដជ្រក ទ្រង់ព្រះកន្សែង
ទន្ទឹះខ្សឹកខ្សួល អាក់អួលម្នាក់ឯង ក្សត្រីថ្វាថ្វែង
បណ្ដាំនូវខ្ញុំ ។
ថានាងក្រាបលា វិលវិញនគរា បុរីរត្នមៀ
នៃព្រះជនក នាងទុកព្រះទំ- រង់រត្នឧត្តម
ទាំង៣នេះនៅ ។
ឲ្យម្ចាស់រក្សា តាងតួជីតា សោះសោកក្ដាត់ក្ដៅ

បើម្ចាស់បងបាន  រួមឋានលំនៅ  ឲ្យម្ចាស់តាមទៅ
ដល់នគរនាយ ។

នាងណែមាគ៌ា  ទិសទីយាត្រា  អំពីឋានអាយ
ឲ្យដូនសមុទ្រ  កំណត់ចម្ងាយ  ដល់នគរនាយ
យោជន៍សាមសិបប្រាំ ។

ពោធិសត្វស្ដាប់  សុនខប្រាយប្រាប់  ដូចពាក្យនាងផ្ដាំ
សព្វគ្រប់សេចគ្រេច  ពាក្យពេចន៍ថៃថាំ  ចិត្តចាប់ចងចាំ
អាល័យក្សត្រី ។

ទ្រង់ព្រះកន្សែង  ពិលាបថ្វាថ្វែង  ឱព្រះប្អូនស្រី
ម្ដេចមកប្រែប្រាស  និរាសចេញពី-  បងបាត់ទៅទី
ទូរឋានឃ្លាតឃ្លា ។

ឱប្អូនបណ្ដូល  បណ្ដាច់ត្រួយត្រួល  សាច់ស្ងួតទ័យា
បងស្មានប្អូនពៅ  នាងនៅគ្រឹហា  ធ្លាប់នែងបរោ
សាន្តសុខបេតី ។

ធ្លាប់នែងនិទ្រា  ពុំដែលឃ្លាតឃ្លា  ដល់មួយរាត្រី
ធ្លាប់រៀបអាហារ  ភ័ស្ដុការចំណី  ទិព្វរសពិសី



ពិសាឲ្យបង ។

ឥឡូវប្អូនពៅ  មាសមេឃ្លាតទៅ  ទីទូរកន្ទង់
ទុកតែទំនេ  បញ្ចង់ហ្នក់ហ្នង  ចាំងបីឲ្យបង
បងរឹតស្រណោះ ។

រឹងគិតដល់ស្ងួន  ពន្ទុកខ្ទឹមខ្លួន  ស្រយុតពុងពោះ
ស្រមើស្រមៃ  ហឫទ័យស្ងួនខ្សោះ  បងរឹងអាឡោះ
អាល័យពេកពន់ ។

ឱប្អូនកល្យាណ  ចិត្តបងគិតស្មាន  ជាប្អូនស្ងួនគន់
នឹងនៅនែបនិត្យ  ស្នេហ៍ស្និទ្ធឥតខ្ពន់  លុះអស់ជីពជន្ម
ជីវិតផងគ្នា ។

មិនដឹងជាប្រាស  ព្រាត់ព្រលឹងមាស  សាច់សង្ក្រា
ពុំបាននៃបនៅ  ទូរទៅឃ្លាតឃ្លា  សមបាបបុណ្យ
បុរិមជាតិ ។

ព្រះពោធិសត្វ  ទួញទៅប្អូនរត្ន  សោកសោយសែនទ្វី
អនាថអាណិត  គន់គិតនារី  រត្នដក្សត្រី
ជៀតប្រាសព្រាកព្រាត់ ។

សោកស្រេចបន្ទោ- ទុក្ខទើបព្រះពោ- ធិវង្សប្រែត្ន
គិតនឹងយាត្រា លីលាទៅថ្វាត់ តាមព្រះប្អូនរ័ត្ន
វរពជធីតា ។

លុះព្រឹកឡើងអ្នក រៀបរាប់ទុកដាក់ ទ្រព្យក្នុងគ្រឹហា
យកតែទម្រង់ បញ្ចូនថ្លៃថ្លា នូវសុនខា
បរចេញពីផ្ទះ ។

ដល់ស្រុកដូនចាស់ មានសប្បុរសណាស់ ជាម្តាយធម៌ព្រះ-
ពោធិចមទៅ ឡើងទៅលើផ្ទះ ទើបអ្នកសំពះ
សួរមាតាធម៌ ។

អ្នកប្រាប់ពីបាន ក្សត្រីកល្យាណ ទ្រង់ដោមលោមពណិ
ប្រាប់ពីស្តេចកាច អំណាចអធម៌ គិតធ្វើអស់អាថិ
ឧបាយកលកិច្ច(១) ។

ដូនចាស់ស្តែងស្តាប់ ពោធិសត្វប្រាប់ សព្វគ្រប់សេចគ្រប

១ ច្បាប់ខ្លះថា អ្នកប្រាប់ពីបាន ក្សត្រីកល្យាណ ទ្រង់ដោមឆាយា ប្រាប់ពីស្តេចកាច កំណាចសហារ គិតធ្វើអស់អាថ៌ ឧបាយកលកិច្ច ។ បើដូច្នេះ ទាល់តែកែសម្រួលឃ្លាខាងដើមថា សួរធម្មមាតា ទៅវិញ ទើបផ្ទួនស្របគ្នានឹងឃ្លា «ទ្រង់ដោមឆាយា» ។



ជីនដើមសេចក្តី អំពីហេតុស្តេច កាចគិតកលកិច្ច
នឹងយកភរិយា ។

ទើបដូនចាស់ឃាត់ ព្រះពោធិសត្វ ឲ្យបរគោគ្គា
គោជន់ក័ស្តុចំណី គ្រកាលពីសា ឃាត់ឲ្យនិទ្រា
នៅមួយរាត្រី ។

លុះព្រឹកព្រាងព្រះ សូរ្យសែងរៀងរះ ពីបូព៌ទិសទី
ទើបអ្នកក្រាបលា យាត្រាចេញខ្ចី ឆ្ពោះតាមទិសទី
ផ្លូវដែលនាងផ្តាំ ។

លេចភ្លេចចូលព្រៃ គ្រមោចពេកក្រៃ ឥតអ្នកណានាំ
មានតែក្តីដឹង ដំណឹងដាក់ចាំ ពាក្យដែលនាងផ្តាំ
នាំអ្នកយាត្រា ។

ចូលក្នុងព្រឹក្សព្រៃ ស្រោងស្រាងគ្រៃឈៃ គ្រឈឹងសាខា
មានដើមស្វាយស្វាត លាំងសាតខ្នុខ្នា លុងល្ហុតសេដា
ដូងដងទន្គ័ល ។

សាច់សីរមាន់មៀន មង្ឃុតធូរេន កៀវញ៉ាសំពីរ

អង្គ្រីនគ្រើលគ្រន់ ស្ពឺស្ពន់សក្បារ ការកេសកែវកា-
ណិកាស្ពុលស្ពាយ ។

ក្ជាំពូក្ជាំពា ក្ជាំពាក់ក្រស្ពា បន្ទន់បារដកពាយ
ដកពក្ខម្ពខ្ទីង ទ្រយឹងរលាយ រលួសវល្លិ៍រាយ
វល្លិ៍វើកធាំធា ។

សណ្ដាសណ្ដាន់ សណ្ដៃកក្រវាន់ ក្រវាញគេកា
ពកុលពេគវាំង លោតលាំងអំពា អំពិលទន្ទា
ទន្ទាប់ផ្ដុះផ្ដាល ។

ព្រីងព្រុសក្របៅ ក្របាសបង្គៅ បង្គាអង្កោល
អង្កាញ់មាក់ប៉ែន គូលេនកណ្ដាល កណ្ដាកត្រសោល
ត្រសិតក្ដាតក្ដួច ។

ស្រឡីស្រឡៅ ស្រឡិតឈើខ្មៅ ឈើខ្ញុញទ្រមួច
ទ្រមែងគ្រញូង ទំពូងសង្ឃ្យប សង្ឃ្យាយពោនពួច
ពកកែពីងពង់ ។

---

មាក់ដោកមាក់ប្រេង មាក្ប្រាងរំដេង រំដួលព្រះគ្រង
ព្រះក្រាបដកម៉ែ ឃ្មាឃ្មៃខ្ញុគខ្នុង ឃ្មាយឃ្មោខ្លុងគង់



គគីរគុយគរ ។

សំរោងសំរក សំរង់គ្រឡក គ្រឡាក់សង្ស័រ
សង្ឃាផ្លាល់មាន់ លំពាន់លំពែរ លំពោះដើមដោះ-
គនក់ក្ដឹងក្ដូ ។

ខន្ធុងខទ្យា ខ្មៅទ្រមន្ទារ- ឫស្សបេងស្រម៉ូវ
សម៉សមូល ពពូលខ្យាខ្យូវ យានយុក្ដាក្ដូវ
ត្រសក់ត្រៀលត្រាចត្រៀក ។

ស្រកាក្ដាមក្ដុល ពុទ្រាទ្រមល់ ទ្រមូងផ្ដៅផ្ដៀក
ស្មៀរស្មៅស្មៃស្មាច់ ព្រាលព្រេចលៀក រលួសកន្ទ្រៀក
កន្ទ្រាកពោធិបាយ ។

អំបែងថ្ងៃថ្ងៃ- សានសោមលាំងដៃ ព្រំព្រះកំបាយ
កំបាត់ស្ដីស្ដៅ ផ្តិលផ្ទៀសណ្ដាយ ក្រកោះគ្រុបក្រាយ
ប្រេសប្រួយជ្រៃជ្រៃ ។

ឈើផងច្រើនពណ៌ ដុះដោយផ្លូវបារ ផ្សេងៗទីទៃ
ផ្លែផ្កាប្រាសប្រាល រន្ទាលក្រាសក្រៃ ដេរដាសដោយព្រៃ
ខុរគមអង្កា ។